ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការរៀបចំនិងការប្រព្រឹត្តទៅរបស់វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ០១ អនក្រ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើតនិងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សានិងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ៨៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

www.pheakdeylaw.com

សម្រេច

មាត្រា១ .-

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ដែលសរសេរជាអក្សរកាត់ថា **វ.ប.ក.** ជាគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ ស្ថិតក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា។

មាត្រា២ .-

វ.ប.ក. មានតួនាទីជាសេនាធិការរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការបណ្តុះបណ្តាលនិស្សិតឱ្យទទួលបានចំណេះដឹងសមស្របទៅតាមតម្រូវការសង្គម មានសមត្ថភាពបំពេញការងារ ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

មាត្រា៣ .-

វ.ប.ក. មានភារកិច្ចបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្ររង បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិត។ **វ.ប.ក.** ត្រូវរៀបចំកម្មវិធីបណ្តុះបណ្តាលដើម្បីដាក់ជូនរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ពិនិត្យនិងសម្រេច។

មាត្រា៤ .-

វ.ប.ក. មានមហាវិទ្យាល័យ សាលាក្រោយបរិញ្ញាបត្រ និងមជ្ឈមណ្ឌលស្រាវជ្រាវនិងនវានុវត្តដូចតទៅ៖

- មហាវិទ្យាល័យបច្ចេកទេសអគ្គិសនី
- មហាវិទ្យាល័យសំណង់
- មហាវិទ្យាល័យវារីសាស្ត្រ
- មហាវិទ្យាល័យរ៉ែនិងភូគព្ភសាស្ត្រ
- មហាវិទ្យាល័យគីមីឧស្សាហកម្ម
- សាលាក្រោយបរិញ្ញាបត្រ
- មជ្ឈមណ្ឌលស្រាវជ្រាវនិងនវានុវត្ត។

វ.ប.ក. អាចស្នើសុំបង្កើតមហាវិទ្យាល័យ មជ្ឈមណ្ឌលស្រាវជ្រាវផ្សេងៗទៀត ដើម្បីដាក់ជូនរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ពិនិត្យនិងសម្រេចតាមនីតិវិធីជាធរមាន។

មាត្រា៥ .-

វ.ប.ក. ត្រូវមានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យនិងសម្រេចលើគោលនយោបាយ ផែនការអភិវឌ្ឍន៍ និងការងារពាក់ព័ន្ធផ្សេងៗទៀតរបស់វិទ្យាស្ថាន។

មាត្រា៦ .-

វ.ប.ក. ត្រូវដឹកនាំដោយនាយកមួយរូបមានឋានៈស្មើអគ្គនាយក និងនាយករងមួយចំនួនមានឋានៈស្មើអគ្គនាយករងតាមការចាំបាច់។

រចនាសម្ព័ន្ធរដ្ឋបាលរបស់ **វ.ប.ក.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

មាត្រា៧ .-

មហាវិទ្យាល័យនីមួយៗ មជ្ឈមណ្ឌលស្រាវជ្រាវ និងសាលាក្រោយបរិញ្ញាបត្រ ត្រូវដឹកនាំដោយព្រឹទ្ធបុរសឬប្រធានមួយរូប មានឋានៈស្មើប្រធាននាយកដ្ឋាន និងព្រឹទ្ធបុរសរងឬអនុប្រធានមួយចំនួនតាមការចាំបាច់។

www.pheakdeylaw.com

តួនាទីនិងភារកិច្ចរបស់មហាវិទ្យាល័យនីមួយៗ មជ្ឈមណ្ឌលស្រាវជ្រាវ និងសាលាក្រោយបរិញ្ញាបត្រ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

មាត្រា៨ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៩ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០១៥

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

ហង់ ជួន ណារ៉ុន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

www.pheakdeylaw.com

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ...៣៥......អនក្រ.បក ចុះថ្ងៃទី..១៧..ខែ......មីនា......ឆ្នាំ២០១៥
ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា



www.pheakdeylaw.com